# ការសិក្សាដើម្បីកែលម្អប្រព័ន្ធប្រតិបត្តិការធនធានសៀវភៅនៅកម្ពុជា

# LIBROS-CAMBODIA

## សៀវភៅសង្ខេប



## សៀវភៅសង្ខេបនេះ

គឺជាការចងក្រងនៃរបកគំហើញពីការសិក្សាស្រាវជ្រាវនៅក្នុងគម្រោងការសិក្សាដើម្បីកែលម្អប្រព័ន្ធប្រតិបត្តិការធនធានសៀវភៅនៅកម្ពុជា។

វានឹងបង្ហាញរូបភាពរួមនៃស្ថានភាពខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅកម្រិតបឋមសិក្សានៅក្នុងប្រទេសកម្ពុជានិងប្រព័ន្ធគ្រប់គ្រងសៀវភៅសិក្សាគោល ត្រៃក អេន ត្រៃស ឬ ធី អេន ធី។

សូមអានរបាយការណ៍ពេញលេញនៃការសិក្សាស្រាវជ្រាវនេះបន្ថែមដើម្បីទទួលបានព័ត៌មានលម្អិត។

# បញ្ជីពាក្យកាត់

| | |
|---|---|
| BSC | Book Supply Chain |
| CSFs | Critical Success Factors |
| DCD | Department of Curriculum Development |
| DIT | Department of Information Technology |
| DoE | District Office of Education |
| EGRA | Early Grade Reading Assessment |
| EMIS | Education Management Information System |
| JSI | John Snow, Inc |
| LIBROS | Learning to Improve Books Resource Operational Systems |
| LMIC | Low-and-Middle-Income Country |
| MEF | Ministry of Economy and Finance |
| MENAP | Multilingual Education National Action Plan |
| MoEYS | Ministry of Education, Youth and Sport |
| MoP | Ministry of Planning |
| NGO | Non-Governmental Organization |
| OPTD | Office of Planning and Textbook Distribution |
| PED | Primary Education Department |
| PDH | Printing and Distribution House |
| PISA-D | Program for International Student Assessment for Development |
| PoE | Provincial Office of Education |
| RGC | Royal Government of Cambodia |
| SSC | School Supporting Committee |
| SMC | School Management Committee |
| TnT | Track and Trace |
| UNESCO | United nations Educational, Scientific and Cultural Organization |
| USAID | United States Agency for International Development |
| WEI | World Education, Inc |

# មាតិកា


០១ ទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅកម្ពុជា

០២ ប្រព័ន្ធអេកូឡូស៊ីភស្តុតាងនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ

០៣ ស្វែងយល់ពីប្រព័ន្ធ ជី អេន ជី

០៤ ខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ មុន និង ក្រោយពេលមាន ជី អេន ជី

០៥ ផលជះ និងបញ្ហាប្រឈម របស់ ជី អេន ជី

០៦ តើយើងទាំងអស់គ្នាអាចធ្វើអ្វីបាន? អនុសាសន៍ទៅអនាគត

# ០១ ទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅកម្ពុជា




ជាទូទៅខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាកម្រិតបឋមនៅក្នុងប្រទេសកម្ពុជាមានប្រាំមួយជំហានរួមមាន(១)ការព្យាករណ៍និងការធ្វើផែនការ(២)ការអភិវឌ្ឍន៍ចំណងជើង (៣) ការបោះពុម្ព (៤) ការធ្វើលទ្ធកម្ម និងការទិញ (៥) ការគ្រប់គ្រងការចែកចាយ និង (៦) ការប្រើប្រាស់សកម្ម ដោយគ្រូ សិស្ស និង ឪពុកម្តាយ។

### ១. ការព្យាករណ៍ និងការធ្វើផែនការ

នេះគឺជាចំណុចចាប់ផ្តើមនៃខ្សែសង្វាក់ដែលយើងធ្វើការវាយតម្លៃពីតម្រូវការសៀវភៅសិក្សានិងសម្ភារៈអំនានផ្សេងៗនិងដើម្បីរៀបចំផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងរយៈពេលវែង។ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅដែលដំណើរការបានល្អ ការព្យាករណ៍ និងការធ្វើផែនការកើតឡើងក្នុងចន្លោះពេលជាក់លាក់។

### ២. ការអភិវឌ្ឍន៍ចំណងជើង

ដំណាក់កាលនេះពាក់ព័ន្ធនឹងការបង្កើតខ្លឹមសារសៀវភៅ ដើម្បីគាំទ្រដល់ការបង្រៀន និងការរៀន។ វាក៏រួមបញ្ចូលផងដែរនូវការបកប្រែខ្លឹមសារសម្រាប់ភាសា និងបរិបទថ្មីៗ ដើម្បីផ្តល់នូវខ្លឹមសារដែលស្របទៅតាមបរិបទរបស់អ្នកសិក្សា។

### ៣. ការបោះពុម្ព

នេះរួមបញ្ចូលទាំងការអភិវឌ្ឍន៍ ការធ្វើទ្រង់ទ្រាយ ការគ្រប់គ្រង ការផ្តល់អាជ្ញាប័ណ្ណសិទ្ធិ និងការស្វែងរកទីផ្សារ ព្រមទាំងការបោះពុម្ពផងដែរ។ ទាំងនេះត្រូវបានចូលរួមដោយវិស័យសាធារណៈ ឬឯកជន ឬតាមរយៈភាពជាដៃគូ។

### ៤. ការធ្វើលទ្ធកម្ម និងការទិញ

នេះពាក់ព័ន្ធនឹងការទិញមាតិកាសៀវភៅ និងសៀវភៅដែលបានបញ្ចប់សព្វគ្រប់ព្រមទាំងសេវាកម្មពាក់ព័ន្ធ។ បរិបទនីមួយៗអាចប្រើប្រភេទលទ្ធកម្មផ្សេងៗគ្នា។

### ៥. ការគ្រប់គ្រងការចែកចាយ

នេះសំដៅលើដំណើរការនៃការបម្លាស់ទីសៀវភៅពីចំណុចផលិតទៅកាន់ចំណុចប្រើប្រាស់ ឬទីតាំងស្តុកទុកបណ្តោះអាសន្ន។

### ៦. ការប្រើប្រាស់

នេះមានន័យថាសៀវភៅត្រូវបានចែកចាយដល់កុមារជាជាងរក្សាទុក ហើយគ្រូបង្រៀនប្រើប្រាស់សៀវភៅយ៉ាងសកម្មសម្រាប់ការណែនាំក្នុងថ្នាក់ (ជាពិសេសសម្រាប់សៀវភៅសិក្សា) និងការអនុវត្តការអាន (ជាពិសេសសម្រាប់សម្ភារៈការអានផ្សេងទៀត)។

# ទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅកម្ពុជា

០១

## បញ្ហាប្រឈមសំខាន់ៗ

ការវិភាគបរិបទបឋមរបស់យើងបានរកឃើញបញ្ហាប្រឈមសំខាន់ៗចំនួនប្រាំនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅកម្រិតបឋមសិក្សានៅកម្ពុជា។ បញ្ហាទាំងនោះក៏មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងកត្តាដែលបង្កវា។



### ការព្យាករណ៍ និងការធ្វើផែនការ

ពេលវេលាដែលចំណាយដើម្បីប្រមូល និងរៀបចំទិន្នន័យតម្រូវការសៀវភៅសិក្សា ភាគច្រើនលើសកាលវិភាគ ឬកាលកំណត់ដែលបណ្តាលឱ្យមានការប្រើប្រាស់ទិន្នន័យចាស់ៗ ឬធ្វើការទស្សន៍ទាយតែម្តង។ បញ្ហានេះរឹតតែធ្ងន់ធ្ងរនៅពេលដែលមានការផ្តល់ទិន្នន័យខុសទោះបីជាការផ្តល់អោយទាន់ពេលវេលាក៏ដោយ។ខណៈពេលដែលនៅកម្រិតសាលាមិនមានការព្យាករជាប្រព័ន្ធ និងផ្លូវការ និងមិនមានផែនការច្បាស់លាស់សម្រាប់សម្ភារៈអំណានផ្សេងទៀត យើងក៏ឃើញមានកង្វះទិន្នន័យតម្រូវការសៀវភៅពីវិស័យឯកជនផងដែរ។

### ការផ្គត់ផ្គង់មិនឆ្លើយតបនឹងតម្រូវការ

យើងបានរកឃើញនូវករណីលើស  កង្វះខាត និងការបាត់បង់សៀវភៅសិក្សាគោលដែលស្នើរសុំ។យើងក៏ឃើញមានករណីដែលសៀវភៅសិក្សាដែលបានចែកចាយខុសពីចំនួននិងចំណងជើងដែលបានស្នើរសុំ។

### ចំនួន និងសមត្ថភាពភាគីពាក់ព័ន្ធនៅមានកម្រិត

ភាគីពាក់ព័ន្ធនឹងការបង្កើតសៀវភៅដែលមានជំនាញ (អ្នកនិពន្ធ អ្នកគំនូរ អ្នកកែសម្រួល អ្នករចនាក្រាហ្វិក អ្នកបោះពុម្ពផ្សាយ និងអ្នកចែកចាយ) នៅមានកម្រិតនៅឡើយ។ កម្មវិធីបណ្តុះបណ្តាលពីការព្យាករណ៍សៀវភៅសិក្សា និងការធ្វើផែនការ និងការគ្រប់គ្រងសៀវភៅក៏មានភាពខ្វះខាតដែរ។

### កង្វះខាតសម្ភារៈអំណានផ្សេងៗ

សម្ភារៈអានបន្ថែមជាច្រើន ភាគច្រើនស្ថិតក្រោមការគាំទ្រ និងការផលិតពីអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតជាជាងរដ្ឋាភិបាល ឬអង្គភាពឯកជន។ សម្ភារៈអានផ្សេងទៀតទាំងនោះក៏មិនទាន់បានរួមបញ្ចូលទៅក្នុងថវិកានៃគោលនយោបាយចែកសៀវភៅឥតគិតថ្លៃរបស់រដ្ឋាភិបាលដែរ។

### កង្វះការយល់ដឹងនិងការអោយតម្លៃលើសៀវភៅ និងការអាន

ខណៈពេលដែលអ្នកបង្កើតសៀវភៅ និងអ្នកចែកចាយមានការយល់ដឹងតិចតួចអំពីទីផ្សារសៀវភៅ បញ្ហាចំបងមួយទៀតនោះគឺកង្វះវប្បធម៌នៃការអាន និងការយល់ដឹងអំពីសារៈសំខាន់នៃសៀវភៅ និងការអាន ជាពិសេសក្នុងចំណោមអាណាព្យាបាលរបស់សិស្ស។ មានអាណាព្យាបាលមួយចំនួនតូចប៉ុណ្ណោះដែលយល់ដឹងពីរបៀបអានដែលអាចជួយកែលម្អការរៀនសូត្ររបស់កូនពួកគេ។ អាណាព្យាបាលខ្លះក៏មិនទាន់យល់និងអោយតម្លៃសៀវភៅរូបភាព និងសម្ភារៈអំណានផ្សេងៗទៀត។

# ទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅកម្ពុជា

# ០១

## មូលហេតុសំខាន់ៗ

យើងឃើញមានមូលហេតុចម្បងចំនួនប្រាំដែលបង្កជាបញ្ហាប្រឈមនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅកម្រិតបឋមនៅកម្ពុជា។ កត្តាទាំងនោះទាក់ទងនឹងការចែកចាយសៀវភៅ ថវិការជាតិមានកម្រិត បរិបទរបស់ប្រទេស គោលនយោបាយ និងគម្លាតចំណេះដឹង។

### ហេដ្ឋារចនាសម្ព័ន្ធ ចំនួន និងសមត្ថភាពនៃសេវាកម្មដឹកជញ្ជូន

ផ្លូវថ្នល់ទៅសាលារៀនមិនទាន់រួចរាល់ និងខូចច្រើន ជាពិសេសសឹងតែមិនអាចចូលបានក្នុងរដូវវស្សា។ កង្វះខាតអគ្គីសនី ទូរគមនាគមន៍និងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណេត។កង្វះខាតអ្នកផ្គល់សេវាកម្មដឹកជញ្ជូនដែលមានជំនាញ ។កង្វះខាតអ្នកលក់ដុំឬលក់រាយសៀវភៅនៅតាមបណ្តាខេត្តជាពិសេសតំបន់ដាច់ស្រយាល។បញ្ហាតម្លៃសៀវភៅខ្ពស់ក្រោយបង់ពន្ធ។ កង្វះកន្លែងផ្ទុកសៀវភៅដែលសមស្របតាមស្តង់ដារ។

### ថវិការមានកំណត់

ថវិការដ្ឋាភិបាលប្រចាំឆ្នាំសម្រាប់សៀវភៅសិក្សាមិនទាន់ឆ្លើយតបទៅនឹងចំនួនដែលបានស្នើសុំនោះទេ។ មកទល់នឹងពេលនេះ ក៏ដូចជាមិនទាន់មានកញ្ចប់ថវិការពីរដ្ឋាភិបាលជាក់លាក់សម្រាប់សម្ភារៈអានបន្ថែមដែលបញ្ហានេះបានធ្លាក់លើស្មារបស់អង្គការក្រៅរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ផ្សេងទៀត។ និរន្តរភាពនៃការគាំទ្ររបស់ពួកគេអាចជាបញ្ហា។ យើងក៏ឃើញមានកង្វះខាតកន្លែងផ្ទុកសៀវភៅដែលសមស្របតាមស្តង់ដារ។

### បរិបទរបស់ប្រទេស

ទោះបីជាកន្លងទៅជាង៤០ឆ្នាំហើយ សង្គ្រាមស៊ីវិលនៅកម្ពុជា ក៏ជាមូលហេតុនៃបញ្ហា។ សង្គ្រាមបានបំផ្លាញវិស័យសំខាន់ៗជាច្រើនរបស់ប្រទេស ជាពិសេសវិស័យអប់រំ និងធនធានមនុស្ស។ ការស្តារឡើងវិញត្រូវការពេលវេលា កិច្ចខិតខំប្រឹងប្រែងរួមគ្នា និងការគាំទ្រ។

### ច្បាប់ និងគោលនយោបាយ

យើងមិនទាន់ឃើញមានការណែនាំច្បាស់លាស់ទាក់ទងនឹងលទ្ធភាពនៃការប្រើប្រាស់សៀវភៅសិក្សាផ្សេងៗពីអ្នកបោះពុម្ពឯកជន។ ដំណើរការរដ្ឋបាល និងលទ្ធកម្មហាក់ដូចជានៅមានភាពតឹងរ៉ឹង និងចំណាយពេលច្រើន។ច្បាប់និងបទប្បញ្ញត្តិស្តីពីការរក្សាសិទ្ធិមិនទាន់មានលក្ខណៈទូលំទូលាយ និងអនុវត្តបានល្អនៅឡើយ។

### គម្លាតចំណេះដឹង

ភស្តុតាងស្រាវជ្រាវក្នុងស្រុកទាក់ទងនឹងវិស័យសៀវភៅគឺនៅមានភាពខ្វះខាត។ ព័ត៌មានទាក់ទងនឹងការផ្លាស់ប្តូរនៅកម្រិតគោលនយោបាយ និងប្រតិបត្តិការគឺមិនតែងតែផ្សព្វផ្សាយជាសាធារណៈ។ មិនទាន់មានយន្តការគ្រប់គ្រាន់ក្នុងការជួយផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធ ឬភស្តុតាងដល់ភាគីពាក់ព័ន្ធ។

# ០២ ប្រព័ន្ធអេកូឡូស៊ីភស្តុតាងនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ




## ភស្តុតាង

ព័ត៌មានជាក់ស្តែង ឬទិន្នន័យដែលផ្អែកលើការសិក្សាវិទ្យាសាស្ត្រ ដូចជាព័ត៌មានដែលលេចឡើងក្នុងអក្សរសិល្ប៍បែបអប់រំ និងក្នុងអក្សរសិល្ប៍ឯកទេស។

## ប្រព័ន្ធអេកូឡូស៊ីភស្តុតាង

សំដៅលើសហគមន៍នៃការប្រាស្រ័យទាក់ទងគ្នារវាងមនុស្ស និងធនធានដែលរួមចំណែកដល់ការបង្កើត ការប្រែសម្រួល និងការប្រើប្រាស់ការស្រាវជ្រាវដែលពាក់ព័ន្ធទៅនឹងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅកម្រិតបឋមកម្ពុជា។

មានតួអង្គសំខាន់បីនៅក្នុងប្រព័ន្ធអេកូឡូស៊ីភស្តុតាង៖ អ្នកបង្កើតភស្តុតាង អ្នកប្រែសម្រួលភស្តុតាង និងអ្នកប្រើប្រាស់ភស្តុតាង។ ភាពខុសគ្នារវាងអ្នកបង្កើត អ្នកប្រែសម្រួល និងអ្នកប្រើប្រាស់ភស្តុតាង គឺផ្អែកលើទំនាក់ទំនងដែលតួអង្គមានជាមួយភស្តុតាងប៉ុន្តែតួអង្គម្នាក់អាចបំពេញតួនាទីច្រើនក្នុងពេលតែមួយ។

ប្រព័ន្ធអេកូឡូស៊ីភស្តុតាងអាចមានតួអង្គដែលអាចឬគួរបំពេញតួនាទីទាំងនេះ ប៉ុន្តែពួកគេមិនទាន់បានចូលរួមយ៉ាងសកម្មនៅឡើយទេ។

# ប្រព័ន្ធអេកូឡូស៊ីភស្តុតាងនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ

# ០២

## ០១ ភស្តុតាង

- របាយការណ៍ស្រាវជ្រាវ
- អត្ថបទទស្សនាវដ្ដីវិទ្យាសាស្ត្រ
- ឯកសារពីសន្និសីទ / សិក្ខាសាលា
- ការអង្កេតបឋម និងចុងក្រោយ

## ០២ ភស្តុតាងបែបផ្សេងទៀត

- មតិយោបល់ពីភាគីពាក់ព័ន្ធ
- ការចែករំលែកបទពិសោធន៍
- សេចក្ដីប្រកាសព័ត៌មាន
- អាជ្ញាធរមូលដ្ឋាន
- ឯកសារច្បាប់,បទប្បញ្ញត្តិ,ការណែនាំ
- របាយការណ៍ពីមូលដ្ឋាន
- ការប្រឹក្សាយោបល់
- បទពិសោធន៍វិជ្ជាជីវៈផ្ទាល់ខ្លួន
- ការសម្រេចចិត្ត ការណែនាំពីអ្នកគ្រប់គ្រង
- ចំណេះដឹងក្នុងស្រុក (ឧ. ចំណេះដឹងជនជាតិដើមភាគតិច)

## ប្រភពភស្តុតាងទាំងបី

### 1 ការប្រមូលទិន្នន័យដោយផ្ទាល់

**អង្គការក្រៅរដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍៖** ការស្ទង់មតិ ការសម្ភាសន៍ និងការពិភាក្សាជាក្រុម។
**រដ្ឋាភិបាល៖** ពីការិយាល័យឬនាយកដ្ឋានពាក់ព័ន្ធ កំណត់ចំណាំពីបេសកកម្ម និងក្រុម Telegram ។

### 2 ការប្រឹក្សាយោបល់

ធាតុចូលដោយផ្ទាល់ពីទីប្រឹក្សាអ្នកជំនាញអ្នកអនុវត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលជារឿយៗអាចស្វែងរកបានតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលា។

### 3 ឯកសាររដ្ឋាភិបាល

ឯកសារច្បាប់, គោលនយោបាយ, របាយការណ៍, និងមូលដ្ឋានទិន្នន័យរបស់រដ្ឋាភិបាល។

---

ដំណើរការទូទៅនៃការប្រើប្រាស់ភស្តុតាងក្នុងវិស័យ **សាធារណៈ និងឯកជន៖**

- ការប្រមូលទិន្នន័យបឋម ឬទទួលបានការណែនាំដោយផ្ទាល់ ឬការណែនាំពីអ្នកគ្រប់គ្រង។
- ធ្វើការសម្រេចចិត្ត និងអនុវត្តសកម្មភាព។

ដំណើរការទូទៅនៃការប្រើប្រាស់ភស្តុតាងក្នុងចំណោម **អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍៖**

- ការកំណត់បញ្ហា(ដោយមានឬគ្មានការយល់ដឹងដោយផ្ទាល់ពីទស្សនិកជនគោលដៅ )។
- ធ្វើការស្រាវជ្រាវជាមូលដ្ឋាន/តម្រង់ទិសសកម្មភាព/ពិសោធន៍លើបញ្ហាដែល បានកំណត់។

- បង្កើតអន្តរាគមន៍ ឬកម្មវិធីដោយផ្អែកលើការយល់ដឹងពីការអង្កេតមូលដ្ឋាន។
- ការវាយតម្លៃកម្មវិធី។
- ការប្រើប្រាស់ការរកឃើញពីការវាយតម្លៃ/ការអង្កេតចុងក្រោយនោះ ដើម្បីពិចារណាជំហានបន្ទាប់។

វាក៏គួរឲ្យកត់សម្គាល់ដែលថាភស្តុតាងស្រាវជ្រាវជាច្រើនដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍គឺមិនតែងតែមានបង្ហាញជាសាធារណៈទេ ភាគច្រើនគឺប្រើសម្រាប់តែការប្រើប្រាស់ ឬការសម្រេចចិត្តផ្ទៃក្នុងប៉ុណ្ណោះ។

# ប្រព័ន្ធអេកូឡូស៊ីភស្តុតាងនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ

# ០២

## ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធអេកូឡូស៊ីភស្តុតាងនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅកម្ពុជា

**G** អ្នកបង្កើតភស្តុតាង

**T** អ្នកប្រែសម្រួលភស្តុតាង

**U** អ្នកប្រើប្រាស់ភស្តុតាង

### ចំណុចដែលពិចារណាតាមភស្តុតាង

G → U

- នៅពេលវិភាគបកស្រាយលទ្ធផលនិងគិតអំពីផលជះរបស់វា។
- នៅពេលបង្កើតសំណួរស្រាវជ្រាវ។
- នៅពេលរៀបចំផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយ។
- នៅក្នុងភាសានិងកម្រិតនៃព័ត៌មានលម្អិតដែលប្រើដើម្បីសរសេរលទ្ធផលស្រាវជ្រាវ។
- នៅពេលជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវ។

### កត្តាលីករ

- ចក្ខុវិស័យ និងបេសកកម្មរបស់ស្ថាប័ន
- ភាពជាដៃគូ ឬការចូលរួមសហការ
- ការមានធនធាន
- ចូលរួមបំពេញចន្លោះចំណេះដឹង
- ចូលរួមបង្កើនចំណេះដឹងដល់សិស្ស
- ឱកាសកែប្រែគោលនយោបាយ

### ឧបសគ្គ

- ចំណាប់អារម្មណ៍ផ្សេងគ្នា
- អ្នកប្រើប្រាស់មិនសូវមានចំណាប់អារម្មណ៍
- ពិបាកទំនាក់ទំនងទៅអ្នកប្រើប្រាស់

### ចំណុចដែលពិចារណាតាមភស្តុតាង

T → U

- ដោយរៀបចំកិច្ចប្រជុំទៀងទាត់ជាមួយទស្សនិកជនគោលដៅ។
- ដោយធ្វើការពិភាក្សាជាក្រុម។
- តាមរយៈការចូលរួមក្នុងក្រុមការងារផ្សេងទៀត និងសហគមន៍អនុវត្ត។
- ដោយសហការជាមួយទស្សនិកជនគោលដៅ។

### កត្តាលីករ

- ចក្ខុវិស័យ និងបេសកកម្មរបស់ស្ថាប័ន
- ភាពជាដៃគូ ឬការចូលរួមសហការ
- ចូលរួមបំពេញចន្លោះចំណេះដឹង
- ឱកាសកែប្រែគោលនយោបាយ

### ឧបសគ្គ

- ចំណាប់អារម្មណ៍ផ្សេងគ្នា
- អ្នកប្រើប្រាស់មិនសូវមានចំណាប់អារម្មណ៍
- ពិបាកទំនាក់ទំនងទៅអ្នកប្រើប្រាស់
- កង្វះខាតធនធានថវិការ
- កង្វះខាតភស្តុតាងដែលមានគុណភាព មានប្រយោជន៍ មានភាពពេញលេញ និងមានតម្លាភាព

### ចំណុចដែលពិចារណាតាមភស្តុតាង

U → G + T

- នៅពេលជ្រើសរើសផ្នែក ឬប្រធានបទអាទិភាព។
- នៅពេលវាយតម្លៃប្រសិទ្ធភាពនៃគោលនយោបាយ ឬកម្មវិធី។
- នៅពេលសម្រេចចិត្តថាត្រូវពង្រីកទំហំអនុវត្តគោលនយោបាយ ឬកម្មវិធី
- នៅពេលរៀបចំគោលនយោបាយ អន្តរាគមន៍ ឬកម្មវិធី។

### កត្តាលីករ

- សក្តានុពលក្នុងការជះឥទ្ធិពលលើលទ្ធផលអប់រំរបស់ប្រជាជន
- ការទទួលស្គាល់វិជ្ជាជីវៈ
- លទ្ធភាពបង្កើនការសហការ
- លទ្ធភាពទទួលបានចំនួលខ្ពស់
- តម្រូវការចាំបាច់របស់ស្ថាប័ន
- ភាពជាដៃគូ ឬការចូលរួមសហការ

### ឧបសគ្គ

- កង្វះខាតធនធានថវិការ
- កង្វះខាតការគាំទ្រ
- កង្វះខាតភស្តុតាងដែលងាយទាញយក
- កង្វះខាតទិន្នន័យ ឬគុណភាពទិន្នន័យនូវមានកម្រិត
- ការស្រាវជ្រាវមិនមានជាអនុសាសន៍គោលនយោបាយ

# ០៣

# ស្វែងយល់ពីប្រព័ន្ធ ជី អេន ជី



# លក្ខណៈ និងមុខងាររបស់ប្រព័ន្ធ ធី អេន ធី (TnT)

TnT គឺជាដំណោះស្រាយឌីជីថលដែលត្រូវបានបង្កើតឡើងដើម្បីជួយគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោលតាមសាលារដ្ឋនៅកម្ពុជា។ វាគឺជាផ្នែកមួយនៃគម្រោង "ការលើកកម្ពស់ការចែកចាយសៀវភៅ នៅកម្ពុជា" ឆ្នាំ ២០១៧-២០១៩ ក្រោមមូលនិធិធនាគារពិភពលោកដល់ អង្គការអប់រំពិភពលោក និងដៃគូរបស់ខ្លួនគឺចន ស្នូ។ ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ជាពិសេសជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការអប់រំពិភពលោក និងដៃគូរបស់ខ្លួនបានសាកល្បង TnT ក្នុងឆ្នាំ ២០១៨ ។ រដ្ឋាភិបាលបានយក និងពង្រីកគម្រោងនេះទូទាំងប្រទេសនៅឆ្នាំ ២០២០ ហើយឥឡូវនេះវាគឺជាប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅគោលជាផ្លូវការ។

TnT ដំណើរការលើ Telegram chatbot សម្រាប់អ្នកប្រើប្រាស់ទូទៅ និងនៅលើផ្ទាំងគ្រប់គ្រងគេហទំព័រសម្រាប់អ្នកគ្រប់គ្រងដូចដែលបានបង្ហាញក្នុងរូបខាងក្រោម។វាមានលក្ខណៈពិសេសសំខាន់ៗចំនួនប្រាំបួនរួមមាន (១) ចុះឈ្មោះនាយកសាលា (២) ធ្វើតម្រូវការសៀវភៅ (៣) ប្រគល់ទទួល (៤) ចំនួនសៀវភៅសិក្សាដែលបានអនុម័ត (៥) ចុះឈ្មោះអ្នកអង្កេតថ្នាក់ (៦) អង្កេតថ្នាក់ (៧) ការរៀនពីរបៀបប្រើប្រាស់ប្រព័ន្ធនេះ (៨) រាយការណ៍បញ្ហា និង (៩) លុបឈ្មោះចេញពី TnT ។ TnT ក៏បានបង្កប់នូវមុខងារពីរផ្សេងទៀតផងដែរគឺ (i) ធ្វើការកែតម្រូវ និង (ii) ព្រីនឯកសារ។




*TnT ត្រូវបានបង្កើតឡើងជាលើកដំបូងជាគំរូដើមនៅក្នុងប្រទេសម៉ាឡាវីកាលពីឆ្នាំ ២០១៦ ក្រោម "All Children Reading Grand Challenge" ដែល USAID រដ្ឋាភិបាលអូស្ត្រាលី និងអង្គការទស្សនៈពិភពលោកផ្តល់មូលនិធិដល់ JSI និង WEI ។

## ០០ ការចូលទៅប្រព័ន្ធ TnT

ជំហានដំបូងក្នុងការប្រើប្រាស់ TnT គឺត្រូវស្វែងរកកម្មវិធី Telegram នៅក្នុងទូរស័ព្ទ។ បន្ទាប់មកត្រូវស្វែងរក “tntcambodia_bot” បន្ទាប់មកចុច “start” ឬវាយ “Hi” (ជាភាសាខ្មែរ ឬភាសាអង់គ្លេស) ដើម្បីចាប់ផ្តើម។

## ០១ ចុះឈ្មោះនាយកសាលា

នាយកសាលាត្រូវតែចុះឈ្មោះបង្កើតគណនីដោយប្រើលេខសម្គាល់ EMIS របស់សាលាពួកគេដើម្បីប្រើប្រាស់ TnT។ សាលាមួយអាចមានគណនីតែមួយប៉ុណ្ណោះ។ មុខងារនេះក៏ត្រូវបានប្រើដើម្បីចុះឈ្មោះ DoE និង PoE ដែលលេខសម្គាល់របស់ពួកគេត្រូវបានបង្កើតដោយអ្នកគ្រប់គ្រង TnT ។

## ០២ ធ្វើតម្រូវការសៀវភៅ

ដើម្បីស្នើសុំសៀវភៅសិក្សាគោល នាយកសាលាត្រូវចុចលើប៊ូតុង "ធ្វើតម្រូវការសៀវភៅ"។ ពួកគាត់ត្រូវផ្តល់ឈ្មោះពេញរបស់គាត់ ចំនួនថ្នាក់រៀន ចំនួនសិស្សប៉ាន់ស្មាន និងចំនួនសៀវភៅសិក្សាគោលដែលមាននៅសល់បច្ចុប្បន្ន។ TnTនឹងគណនាចំនួនសៀវភៅសិក្សាដែលសាលាត្រូវស្នើសុំដោយស្វ័យប្រវត្តិ ហើយផ្ញើសេចក្តីសង្ខេបទៅក្នុងប្រអប់ឆាតរបស់នាយកសាលា

## ០៣ ប្រគល់ទទួល

នាយកសាលាប្រើមុខងារនេះដើម្បីកត់ត្រាចំនួនពិតប្រាកដនៃសៀវភៅសិក្សាគោលដែលបានទទួល។ ពួកគាត់នឹងបញ្ចូលទិន្នន័យម្តងមួយៗតាមមុខវិជ្ជានិងកម្រិតថ្នាក់ ហើយប្រសិនបើមានភាពមិនស៊ីគ្នា ពួកគាត់នឹងរាយការណ៍បញ្ហានេះដោយប្រើមុខងារ "រាយការណ៍បញ្ហា"។

## ០៤ ចំនួនសៀវភៅអនុម័ត

មុខងារនេះអនុញ្ញាតឱ្យនាយកសាលាពិនិត្យមើលចំនួនសៀវភៅសិក្សាដែលត្រូវបានអនុម័តសម្រាប់សាលារបស់ពួកគេ។ ពួកគេអាចប្រើព័ត៌មាននេះដើម្បីត្រួតពិនិត្យជាមួយចំនួនពិតនៃសៀវភៅសិក្សាដែលបានដឹកជញ្ជូន ឬទទួល។

## ០៥ ចុះឈ្មោះអ្នកអង្កេតថ្នាក់

អ្នកអង្កេតថ្នាក់មិនមែនជានាយកសាលាទេ ប៉ុន្តែពួកគេអាចជាសមាជិកនៃសហគមគាំទ្រសាលារៀន បុគ្គលិកសាលា ឬមន្ត្រីពីក្រសួង។ ពួកគេជួយពិនិត្យតាមដាននូវចំនួន និងស្ថានភាពនៃសៀវភៅសិក្សាដែលបានផ្គត់ផ្គង់។

## ០៦ អង្កេតថ្នាក់

អ្នកអង្កេតថ្នាក់ប្រើមុខងារនេះដើម្បីត្រួតពិនិត្យថ្នាក់រៀន។ ពួកគេនឹងផ្តល់ព័ត៌មានអំពីចំនួនសិស្ស ក្នុងថ្នាក់រៀន ចំនួនសិស្សដែលមានសៀវភៅសិក្សានិងចំនួនសៀវភៅសិក្សាដែលមានត្រា "សម្រាប់លក់"។ ពួកគេក៏អាចធ្វើការកែតម្រូវ ឬព្រីនទម្រង់មុនពេលដាក់ស្នើទៅក្នុងប្រព័ន្ធ។

## ០៧ រៀនពីរបៀបប្រើប្រព័ន្ធ

ប៊ូតុងមុខងារនេះនឹងនាំអ្នកប្រើប្រាស់ TnT ទៅកាន់តំណភ្ជាប់ដែលមានវីដេអូណែនាំខ្លីៗ ក៏ដូចជាមានឯកសារមួយ ឬពីរទំព័រ ណែនាំអំពីរបៀបប្រើប្រាស់ប្រព័ន្ធ TnT ។ សេចក្តីណែនាំ និងការបង្រៀនទាំងនោះភាគច្រើនធ្វើជាភាសាខ្មែរ។

## ០៨ រាយការណ៍បញ្ហា

អ្នកប្រើប្រាស់អាចរាយការណ៍បញ្ហាអ្វីដែលគេជួបប្រទះជាមួយ TnT ឬភាពមិនសមស្របគ្នានៃសៀវភៅសិក្សាដែលស្នើរសុំនិងផ្គត់ផ្គង់ដោយប្រើមុខងារនេះ។ អ្នកគ្រប់គ្រង TnT នឹងពិនិត្យមើលហើយជួយដោះស្រាយបញ្ហា។

## ០៩ លុបឈ្មោះចេញពីប្រព័ន្ធ

ដើម្បីលុបគណនី TnT នាយកសាលាត្រូវចូលទៅកាន់កម្មវិធីហើយចុចលើប៊ូតុងមុខងារ "លុបគណនី" ។

មុខងារ "ធ្វើការកែតម្រូវ" និង "ព្រីនឯកសារ" បានបង្កប់នៅក្នុង មុខងារធ្វើតម្រូវការសៀវភៅ ប្រគល់ទទួល និងមុខងារអង្កេតថ្នាក់រៀន។ មុខងារទាំងនេះមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ TnT ទាក់ទងនឹងការកែកំហុសដែលអចេតនា ឬសម្រាប់គោលបំណងរក្សាឯកសារ ប៉ុន្តែមុខងារទាំងនេះអាចប្រើបានតែមុនពេលធ្វើការដាក់បញ្ចូលទៅក្នុងប្រព័ន្ធ។

# ដំណើរការនៃប្រព័ន្ធ ធី អេន ធី (TnT)




មុខងារ TnT ពីរដែលត្រូវបានគេប្រើញឹកញាប់បំផុតគឺ "ធ្វើតម្រូវ ការសៀវភៅ" និង "ប្រគល់ទទួល"។ នាយកសាលាគឺជាអ្នកប្រើប្រាស់សំខាន់នៃ TnT ហើយពួកគេភាគច្រើនប្រើវាពីរដងក្នុងមួយឆ្នាំសម្រាប់មុខងារទាំងពីរនេះ។ DoEs និង PoEs ក៏ប្រើ TnT ដើម្បីបញ្ជាក់បង្កាន់ដៃសៀវភៅសិក្សាផងដែរ។

មានតែប្រមាណជា៥០%នៃនាយកសាលាដែលបានចូលរួមក្នុងការស្ទង់មតិរបស់យើងបានរាយការណ៍ថាបានប្រើមុខងារ "ចុះឈ្មោះសម្រាប់នាយកសាលា" និង "រៀនពីរបៀប ប្រើ" ។ តិចជាង ២០% នៃនាយកសាលាបានប្រើមុខងារ TnT ផ្សេងទៀត។

ការសម្ភាសជាមួយក្រុមកម្រិតប្រតិបត្តិការបានបង្ហាញថាអ្នកឆ្លើយសំណួរមួយចំនួនប្រហែលជាបានស្វែងរកការគាំទ្រពីអ្នកដទៃដើម្បីប្រើប្រាស់មុខងារផ្សេងទៀតរបស់ TnT ហើយអ្នកខ្លះបានប្រើមុខងារផ្សេងទៀតនៅពេលដែលពួកគេទទួលបានការណែនាំពីថ្នាក់លើរបស់គេ។ អ្នកចូលរួមខ្លះមិនហ៊ានប្រើព្រោះខ្លាចធ្វើឲ្យមានកំហុសក្នុងប្រព័ន្ធ។

# ០៤

# ខ្សែសង្វាក់ផ្គត់ផ្គង់
# សៀវភៅសិក្សាគោល




## មុន និងក្រោយពេលមាន

# TnT

# តំណាងនៃតួអង្គសំខាន់ៗក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោល



គណៈកម្មាធិការគាំទ្រ ឬគ្រប់គ្រងសាលា (SMC/SSC)



ការិយាល័យផែនការ និងផ្គត់ផ្គង់សៀវភៅសិក្សាគោល (OPTD)



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (PDH)



នាយកសាលា (SD)




វិស័យឯកជន (PS)



ដៃគូអភិវឌ្ឍន៍ និងអនុវត្ត (D&IP)



ការិយាល័យអប់រំខេត្ត (PoE) និង ការិយាល័យអប់រំស្រុក (DoE)



ក្រសួងផ្សេងទៀត

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ទំនាក់ទំនង (MPTC)
- ក្រសួងពាណិជ្ជកម្ម (MoC)



ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)

# ការប្រែប្រួលនៃតួនាទីរបស់តួអង្គ

## ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោល

| មុនពេលមាន TnT | | ក្រោយពេលមាន TnT |
|---|---|---|
| ១. ប្រមូលទិន្នន័យទាក់ទងនឹងសៀវភៅសិក្សាគោល ដើម្បីព្យាករណ៍តម្រូវការសៀវភៅសិក្សាគោល និងធ្វើសំណើសុំ (ជាច្បាប់ចម្លងរឹង)។<br>២. បញ្ជូនច្បាប់ចម្លងរឹងនៃសំណើសៀវភៅសិក្សាគោលរបស់សាលាពួកគេទៅ DoE, PoE និង OPTD ។<br>៣. ទៅទទួលយកសៀវភៅសិក្សាគោលដែលបានផ្គត់ផ្គង់ ហើយចុះហត្ថលេខាលើបង្កាន់ដៃប្រគល់ទទួល។<br>៤. ចែកសៀវភៅសិក្សាគោលដល់សិស្ស។ | **នាយកសាលា**<br> | ១. ប្រមូលទិន្នន័យដែលទាក់ទងនឹងសៀវភៅសិក្សាគោល ដើម្បីបំពេញទម្រង់តម្រូវការសៀវភៅសិក្សាគោលនៅក្នុង TnT ។<br>២. បញ្ជូនសំណើសៀវភៅសិក្សាគោលរបស់សាលាពួកគេទៅក្នុង TnT។<br>៣. ទៅទទួលយកសៀវភៅសិក្សាគោលដែលបានផ្គត់ផ្គង់ ហើយចុះហត្ថលេខាលើបង្កាន់ដៃប្រគល់ទទួល។<br>៤. បំពេញទម្រង់ប្រគល់ទទួលតាម TnT។<br>៥. ចែកសៀវភៅសិក្សាគោលដល់សិស្ស។ |
| ១. ជូនដំណឹងដល់ SD ដើម្បីបំពេញទម្រង់ស្នើសុំសៀវភៅសិក្សាគោល។<br>២. ពិនិត្យសំណើសៀវភៅសិក្សាគោលដែលដាក់ជូនដោយនាយកសាលានៅក្នុងស្រុករបស់ពួកគេ។<br>៣. រៀបចំសំណើសៀវភៅសិក្សាគោលទាំងអស់ទៅក្នុងទម្រង់ស្នើសុំសៀវភៅសិក្សាគោលតែមួយសម្រាប់ស្រុករបស់ពួកគេ។<br>៤. បញ្ជូនច្បាប់ចម្លងរឹងនៃសំណើសៀវភៅសិក្សាគោលរួម និងឯកសារយោងទៅអោយ PoE និង OPTD។ | **ការិយាល័យអប់រំស្រុក**<br> | ១.សម្របសម្រួលជាមួយសាលារៀនណាដែលមិនទាន់បំពេញតម្រូវការសៀវភៅសិក្សាគោល និងការប្រគល់ទទួលតាមរយៈ TnT ដើម្បីអោយឆាប់បំពេញ។<br>២. បំពេញទម្រង់ប្រគល់ទទួលតាម TnT ។<br>៣. ជួយបង្រៀន និងណែនាំពីការប្រើប្រាស់ TnT ទៅកាន់នាយកសាលា និងអ្នកប្រើប្រាស់ផ្សេងទៀត។ |
| ១. ពិនិត្យសំណើសៀវភៅសិក្សាគោលរួមដែលដាក់ជូនដោយ DoEs ក្នុងខេត្តរបស់ពួកគេ។<br>២. រៀបចំសំណើសៀវភៅសិក្សាគោលទាំងអស់ទៅក្នុងទម្រង់ស្នើសុំសៀវភៅសិក្សាគោលតែមួយសម្រាប់ខេត្តរបស់ពួកគេ។<br>៣. បញ្ជូនច្បាប់ចម្លងរឹងនៃសំណើសៀវភៅសិក្សាគោលរួម និងឯកសារយោងទៅអោយ PoE និង OPTD។ | **ការិយាល័យអប់រំខេត្ត**<br> | ១. បំពេញទម្រង់ប្រគល់ទទួលតាម TnT ។<br>២. ជួយបង្រៀន និងណែនាំពីការប្រើប្រាស់ TnT ទៅកាន់នាយកសាលា និងអ្នកប្រើប្រាស់ផ្សេងទៀត។ |

# ការប្រែប្រួលនៃតួនាទីរបស់តួអង្គ

## ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោល

| មុនពេលមាន TnT | | ក្រោយពេលមាន TnT |
|---|---|---|
| ១. ពិនិត្យនិងបញ្ចូលទិន្នន័យតម្រូវការសៀវភៅសិក្សាគោលទៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់ពួកគេ។<br>២. កែកុនតំរូវការសៀវភៅសិក្សា គោលហើយដាក់ជូនទៅអង្គភាពលទ្ធកម្មក្នុងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធ្វើការស្នើរសុំការធានាថវិកាបោះពុម្ពសៀវភៅសិក្សាគោល។<br>៣. ផ្ញើបញ្ជីសៀវភៅសិក្សាគោលដែលត្រូវបានអនុម័តបោះពុម្ពចុងក្រោយទៅ PDH និង/ឬក្រុមហ៊ុនបោះពុម្ពដែលឈ្នះការដេញថ្លៃសម្រាប់ការបោះពុម្ព។ | **ការិយាល័យផែនការ និងផ្គត់ផ្គង់សៀវភៅសិក្សាគោល**<br> | ១. ពិនិត្យ និងអនុម័តលើតម្រូវការសៀវភៅសិក្សាគោល និងបញ្ជីបែងចែក។ |
| ១. ពិនិត្យមើលបញ្ជីបោះពុម្ពសៀវភៅគោល បោះពុម្ព និងវេចខ្ចប់។<br>២. រៀបចំបញ្ជីកាលវិភាគចែកចាយ និងបញ្ជូនសៀវភៅសិក្សាគោលទៅសាលារៀន ឬ DoE ឬ PoE ។<br>៣.ប្រមូលបង្កាន់ដៃប្រគល់ទទួលសៀវភៅសិក្សាគោលនិងបង្កាន់ដៃដឹកជញ្ជូនសម្រាប់ជាឯកសារយោង។ | **គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ**<br> | ១.ពិនិត្យមើលទិន្នន័យតម្រូវការសៀវភៅសិក្សាគោលនិងទិន្នន័យប្រគល់ទទួលនៅក្នុងផ្ទាំងក្តារខៀនគ្រប់គ្រងឌីជីថល TnT ។<br>២. រៀបចំបញ្ជីកាលវិភាគចែកចាយ និងដឹកសៀវភៅសិក្សាគោលទៅសាលារៀន ឬសាលាកម្រង ឬ DoE ឬ PoE ។<br>៣.ប្រមូលបង្កាន់ដៃប្រគល់ទទួលសៀវភៅសិក្សាគោលនិងបង្កាន់ដៃដឹកជញ្ជូនសម្រាប់ជាឯកសារយោង។<br>៤. ជួយបង្រៀន និងណែនាំពីការប្រើប្រាស់ TnT ទៅកាន់នាយកសាលា និងអ្នកប្រើប្រាស់ផ្សេងទៀត។ |
| • មិនពាក់ព័ន្ធ<br>• ការផ្តល់ជំនួយជាសៀវភៅសិក្សាតាមលទ្ធភាព | **គណៈកម្មាធិការគាំទ្រ ឬគ្រប់គ្រង សាលា**<br> | • ធ្វើការអង្កេតថ្នាក់រៀន<br>• ការផ្តល់ជំនួយជាសៀវភៅសិក្សាតាមលទ្ធភាព |

# ការប្រែប្រួលនៃតួនាទីរបស់តួអង្គ

## ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោល

| **មុនពេលមាន TnT** | **ក្រោយពេលមាន TnT** |
| --- | --- |

ក្រសួងអប់រំ យុវជន និងកីឡា



០. ពិនិត្យ និងធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សា និងកម្មវិធីសិក្សា។
១. ពិនិត្យ និងអនុម័តសំណើសៀវភៅសិក្សាគោល និងថវិកាផ្គត់ផ្គង់។
២. ពិនិត្យ និងអនុម័តដំណើរការលទ្ធកម្មសម្រាប់ការបោះពុម្ព សៀវភៅសិក្សាគោល។

០. ពិនិត្យ និងធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សា និងកម្មវិធីសិក្សា។
១. ពិនិត្យ និងអនុម័តសំណើសៀវភៅសិក្សាគោល និងថវិកាផ្គត់ផ្គង់។
២. ពិនិត្យ និងអនុម័តដំណើរការលទ្ធកម្មសម្រាប់ការបោះពុម្ព សៀវភៅសិក្សាគោល។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



# ខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោល

# មុន TnT



# ក្រោយ TnT

ខ្សែសង្វាក់ផ្គត់ផ្គង់
សៀវភៅសិក្សាគោល



# ០៥

# TnT ផលជះ និង បញ្ហាប្រឈម



# ផលផលរបស់ TnT

១

### ជួយសន្សំពេលវេលា៖

TnT ធ្វើស្វ័យប្រវត្តិកម្មការព្យាករណ៍ និងការធ្វើតម្រូវការសៀវភៅសិក្សាគោល ដោយមិនចាំបាច់អោយមានការគណនាដោយដៃនិងការបញ្ជូនឯកសារជាក្រដាស ពីនាយកសាលារៀន។

TnT ក៏អនុញ្ញាតឱ្យ PDH ទាក់ទងដោយផ្ទាល់ជាមួយនាយកសាលា ដោយកាត់បន្ថយតម្រូវកាចូលរួមពី DoE និង PoE ។ វាជួយសន្សំពេល PDH ពី ២-៤ សប្តាហ៍ក្នុងការព្យាករណ៍តម្រូវការសៀវភៅសិក្សាគោល និងការធ្វើផែនការ ហើយ OPTD លែងត្រូវការបញ្ចូលទិន្នន័យពីនាយកសាលាទៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់ពួកគេទៀតហើយ។

២

### ជួយសន្សំធនធានមនុស្ស និងថវិការ៖

TnT បានសម្រួលការគ្រប់គ្រងសៀវភៅសិក្សាគោល សន្សំពេលវេលា ថវិកា និងធនធាន។

ទោះបីជានាយកសាលាទាំងអស់មិនបានបានបញ្ជាក់ថាឥឡូវនេះ ពួកគាត់អាចចំណាយលើការដឹកជញ្ជូនសៀវភៅសិក្សាតិចជាងមុនក៏ដោយ ក៏ប្រមាណជា ៦០ %នៃនាយកសាលាបានបញ្ជាក់ថាក្រុមហ៊ុនបោះពុម្ពនិងក្រុមហ៊ុនចែកចាយ (PDH និង Sindy), DoE, PoE, សាលាកម្រងឬសាលារៀនក្បែរនោះនឹងជួយដឹកជញ្ជូនសៀវភៅដល់ សាលារបស់ពួកគេដោយផ្ទាល់។

៣

### ជួយបង្កើនលទ្ធភាពទទួលបានសៀវភៅសិក្សាគោលដល់សិស្ស៖

TnT បានជម្រុញការទទួលបានសៀវភៅសិក្សាគោលដល់សិស្សអោយរឹតតែប្រសើរឡើងដោយធ្វើឱ្យដំណើរការស្មើសុំរហ័សជាងមុន ធានាថាសៀវភៅសិក្សាត្រឹមត្រូវត្រូវបានចែកចាយ និងពន្លឿនការដឹកជញ្ជូន។

ការស្ទង់មតិរបស់យើងជាមួយនាយកសាលាបានរកឃើញថា ៧៩%នៃពួកគាត់យល់ស្របថា TnT បានជួយសាលារៀនរបស់ពួកគាត់ឱ្យទទួលបានសៀវភៅសិក្សាលឿនជាងមុន ហើយអ្នកខ្លះថែមទាំងទទួលបានសៀវភៅសិក្សាមុនឆ្នាំសិក្សាថ្មីចាប់ផ្តើម។ ចំនួននៃសាលារៀនដែលមានសិស្ស១០០%ទទួលបានសៀវភៅសិក្សាគ្រប់មុខវិជ្ជាបានកើនឡើងពី ៣៨% ទៅ ៧៥% ។

៤

### ជួយបង្កើនតម្លាភាព និងគណនេយ្យភាព៖

TnT ធ្វើឌីជីថលនីយកម្មខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោល ធ្វើឱ្យវាកាន់តែមានតម្លាភាព និងគណនេយ្យភាព។

TnT ធ្វើឱ្យកាន់តែមានភាពងាយស្រួលក្នុងការតាមដានចលនានៃសៀវភៅសិក្សាគោល និងធានាថាសៀវភៅទាំងនោះត្រូវបានបញ្ជូនទៅត្រូវសាលា។វាក៏អនុញ្ញាតឱ្យសាលារៀនធ្វើការត្រួតពិនិត្យចំនួនផ្លូវការនៃសៀវភៅសិក្សាដែលបានអនុម័តនៅក្នុង TnT ហើយពិនិត្យមើល និងរាប់វានៅកន្លែងចែកចាយជាមួយនឹងបង្កាន់ដៃប្រគល់ទទួលនិងដឹកជញ្ជូន។

# ស្ថានភាពសៀវភៅសិក្សាគោល

១: មិនដែលជួបប្រទះទាល់តែសោះ , ២: កម្រជួបប្រទះ , ៣: ជួបប្រទះម្តងម្កាល, ៤: ជួបប្រទះជារឿយៗ, ៥: តែងតែជួបប្រទះ




## IMPACTS OF TnT

### Forecasting & Planning

By using TnT, my school can:

- Submit the textbook request within the approved timeframe.
- Submit the textbook request faster than before.
- Calculate the right amount of demanded textbooks.
- Calculate the right demanded textbook title.

### Distribution & Delivery

By using TnT, my school:

- Can easily track textbook shipments.
- Is notified on textbook arrival
- Is notified on the expected delivery date.
- Is notified on which delivery company will deliver.
- Can receive the requested textbooks faster.
- Can receive the right number of requested textbooks.
- Can receive the right number of requested textbook titles.
- Can receive the requested textbooks in good quality.
- Can help cross-check the amount, titles, and quality.

### Inquiry & Feedback

By using TnT, my school can:

- Easily submit any inquiry regarding textbooks via TnT Chatbot.
- Promptly receive responses on any inquiry regarding textbooks via TnT Chatbot.
- Easily request to change any wrong textbook order.
- Easily request to change any textbooks damaged during shipment or distribution.

| | Forecasting & Planning | Distribution & Delivery | Inquiry & Feedback |
|---|---|---|---|
| មិនយល់ស្របទាល់តែសោះ | 0% | 0% | 0% |
| មិនយល់ស្រប | 0% | 1% | 0% |
| ពិបាកសម្រេចចិត្ត | 2% | 3% | 7% |
| យល់ស្រប | 79% | 79% | 77% |
| យល់ស្របទាំងស្រុង | 19% | 17% | 15% |

# បញ្ហាប្រឈមរបស់ TnT

១

**គម្លាតឌីជីថល៖**

បញ្ហានេះគ្របដណ្ដប់តាំងពីវិសមភាពនៃ ការអាចចូលទៅប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល រហូតដល់បញ្ហាដែលទាក់ទងនឹងតម្រូវការសមត្ថភាពនិងលទ្ធភាពទាញយកខ្លឹមសារឬធនធានដែលមាននៅក្នុងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។

នាយកសាលាមួយចំនួនមិនមានលទ្ធភាពប្រើប្រាស់ឧបករណ៍ឌីជីថលនិងអ៊ីនធឺណិតនៅឡើយ។ទោះបីជានាយកសាលាខ្លះមានលទ្ធភាពប្រើប្រាស់ឧបករណ៍ឌីជីថល និងអ៊ីនធឺណិត ក៏ពួកគាត់មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់TnTពេញលេញដែរ។ផ្នែកខ្លះនៃប្រព័ន្ធនេះនៅជាភាសាអង់គ្លេសហើយមុខងារមួយចំនួនក៏នៅមានការពិបាកប្រើ។

២

**បញ្ហាផ្ទៃមុខងារ៖**

អ្នកប្រើប្រាស់TnTមួយចំនួនបានបង្ហាញថាផ្ទៃមុខងារ TnT នៅមានភាពស្មុគស្មាញ និងពិបាកប្រើប្រាស់នៅឡើយជាពិសេសបើសិនជាប្រើនៅលើទូរសព្ទដៃ។

ពួកគាត់ក៏មានបញ្ហាក្នុងការស្វែងរកមុខងារព្រីនសំណើតម្រូវការ និងការប្រគល់ទទួលសៀវភៅសិក្សាគោលរបស់ពួកគាត់ ឬក៏នៅពេលដែលពួកគាត់ចង់ធ្វើការកែតម្រូវនានា។នេះដោយសារតែមុខងារទាំងនេះត្រូវបានសរសេរជាភាសាអង់គ្លេសហើយវាត្រូវបានគេតាងដោយរូបតំណាងតូចៗ ដែលអាចពិបាកមើល ឬយល់។

៣

**មុខងារមិនទាន់ឆ្លើយតបតម្រូវការ និងកង្វះខាតថវិកាក្នុងការកែលម្អប្រព័ន្ធ៖**

បច្ចុប្បន្ននេះ TnT មិនមែនជាប្រព័ន្ធពេញលេញទៀតទេ។ មុខងារមួយចំនួនត្រូវបានដកចេញ ហើយមុខងារផ្សេងទៀតក៏មិនឆ្លើយតបទៅនឹងតម្រូវការ។

ឧទាហរណ៍ សមត្ថភាពក្នុងការតាមដានដំណើរការដឹកជញ្ជូននិងការចែកចាយសៀវភៅសិក្សាគោលត្រូវបានដកចេញ។ចំនួនអ្នកអាចចូលទៅប្រើប្រាស់ផ្ទាំងមុខងារក៏ត្រូវបានបន្ថយស្របពេលដែលមានមនុស្សតែម្នាក់ប៉ុណ្ណោះក្នុងមួយសាលាដែលត្រូវបានអនុញ្ញាតឱ្យប្រើ TnT ។ យើងឃើញមានគោលបំណងក្នុងការធ្វើឱ្យ TnT ប្រសើរឡើង ប៉ុន្តែវាមិនទាន់អាចធ្វើទៅបាន ដោយសារបញ្ហាចំណាយខ្ពស់ជាមួយក្រុមហ៊ុនបរទេស ។

៤

**កង្វះខាតការបណ្ដុះបណ្ដាល៖**

នាយកសាលាជាច្រើនមិនទាន់ទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ពីរបៀបប្រើប្រាស់ TnT។ ការស្ទង់មតិរបស់យើងបានបង្ហាញថាមានតែ ៣៣.៧%នៃនាយកសាលាធ្លាប់ទទួលបានការបណ្ដុះបណ្ដាលលើការប្រើប្រាស់ TnT ។

យើងឃើញថាមានឯកសារណែនាំតាមអ៊ីនធឺណិតមួយចំនួនដែលមានទម្រង់ជាឯកសារមួយឬពីរទំព័រនិងវីដេអូណែនាំដែលមានចលនាខ្លីៗ ប៉ុន្តែមិនមានអ្នកប្រើប្រាស់ច្រើនទេដែលបានដឹងអំពីវា។ខ្លឹមសារនៃឯកសារណែនាំទាំងនោះក៏ត្រូវបានសង្កេតឃើញថានូវមិនទាន់គ្របដណ្ដប់ពេញលេញនូវមុខងារTnTដែលមានស្រាប់ទាំងអស់ទេ។

# ០៦

## តើយើងទាំងអស់គ្នាអាចធ្វើអ្វីបានខ្លះ?

## អនុសាសន៍



# ១. គម្លាតសមត្ថភាពរបស់អ្នកប្រើប្រាស់

## MOEYS

១ ផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់ និងផ្តល់ជាការរំលឹកអំពីរបៀបប្រើ TnT ក៏ដូចជាការព្យាករណ៍ និងការគ្រប់គ្រងសៀវភៅសិក្សាអោយមានប្រសិទ្ធភាព និងមានស្តង់ដារ។

២ បញ្ចូលការបណ្តុះបណ្តាលពីការប្រើប្រាស់ TnT ទៅក្នុងការបណ្តុះបណ្តាលនាយកសាលា និងក្នុងអំឡុងពេលការណែនាំតម្រង់ទិសនៃការបើកបវេសនកាលឆ្នាំសិក្សាថ្មី។

## PDH

១ បញ្ចូលភាសាខ្មែរឱ្យពេញលេញទៅក្នុង TnT ។







## D&IP

១ ចែករំលែកការអនុវត្តល្អៗលើការគ្រប់គ្រងសៀវភៅ និងការបណ្តុះបណ្តាលពាក់ព័ន្ធដល់សាលារៀន។

## SD, DoE & PoE, SSC

១ ចូលរួមអោយសកម្មក្នុងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធដែលអាចជួយបង្កើនសមត្ថភាពក្នុងការប្រើប្រាស់ TnT និងការគ្រប់គ្រងសៀវភៅសិក្សាគោល។

២ ធ្វើការរំលឹក និងអនុវត្តជាប្រចាំនូវខ្លឹមសារពីការបណ្តុះបណ្តាលណាមួយដែលទទួលបាន។




## PS

១ ចែករំលែកការអនុវត្តល្អលើការគ្រប់គ្រងសៀវភៅ។

# ២. គម្លាតឌីជីថល

## RGC

១ វិនិយោគលើការកែលម្អប្រព័ន្ធប្រើប្រាស់ ហេដ្ឋារចនាសម្ព័ន្ធ និងការភ្ជាប់សេវាអ៊ីនធឺណិតទូទាំងខេត្ត ជាពិសេសនៅក្រៅតំបន់ទីប្រជុំជន។

២ បង្កើនទំនួលខុសត្រូវសង្គមរួម ដើម្បីឱ្យមានការចូលរួមកាន់តែច្រើនពីវិស័យឯកជន។

## MOEYS

១ បែងចែកថវិការបស់ក្រសួងជាក់ច្បាស់ ដើម្បីទិញ បំពាក់ និងថែរក្សាសម្ភារៈបរិក្ខារចាំបាច់នានា ជាពិសេសបរិក្ខារឌីជីថលទូទាំងសាលារៀនក្នុងប្រទេសកម្ពុជា។

២ ជូនដំណឹង និងណែនាំសាលាឱ្យប្រើប្រាស់កញ្ចប់ជំនួយសម្រាប់ការកែលម្អសាលារៀន (SIG) និងមូលនិធិប្រតិបត្តិការសាលា (SOF) អោយមានប្រសិទ្ធភាព ។

៣ បង្កើតវិធីសាស្ត្រ ឬមធ្យោបាយដែលអនុញ្ញាតឱ្យមានការចូលរួម និងភាពជាដៃគូពីវិស័យឯកជនអោយបានច្រើន។







## SD

១ ប្រើប្រាស់កញ្ចប់ជំនួយសម្រាប់ការកែលម្អសាលារៀន (SIG) និងមូលនិធិប្រតិបត្តិការសាលា (SOF) អោយមានប្រសិទ្ធភាព ។

២ ព្យាយាមបង្កើត និងពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន។

## PS

១ ចូលរួមអោយបានសកម្មក្នុងការទទួលខុសត្រូវសង្គមរួមក្នុងរូបភាពជាការឧបត្ថម្ភថវិការឬដោយរបស់សប្បុរសវត្ថុ (ដូចជាគ្រឿងបរិក្ខារ មូលនិធិ អាហារូបករណ៍។ល។)

# ៣. បញ្ហាបច្ចេកទេសរបស់ប្រព័ន្ធ

## PDH

១ ចងក្រងបញ្ជីបញ្ហា និងមុខងារបច្ចេកទេសនៅក្នុង TnT ដែលចាំបាច់ត្រូវកែតម្រូវឡើងវិញ បន្តដំណើរការ លុបចោល ឬបង្កើតថ្មី។

២ ប្រមូលផ្តុំធាតុចូលជាមតិ ឬមូលនិធិពីក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធ ដើម្បីជួយដោះស្រាយបញ្ហាបច្ចេកទេសនៅក្នុង TnT និងធ្វើមូលដ្ឋានីយកម្មTnT (ប្រែសម្រួលអោយទៅជាប្រព័ន្ធក្នុងស្រុក)។

៣ បើកការអំពាវនាវជាសាធារណៈដើម្បីឱ្យក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ឬក្រុមហ៊ុនអភិវឌ្ឍន៍កម្មវិធីបង្ហាញពីចំណាប់អារម្មណ៍របស់ពួកគេក្នុងការកែលម្អ TnT ។




## PS

១ ចូលរួមឱ្យបានសកម្មក្នុងការផ្តល់ការពិគ្រោះយោបល់ ឬដំណោះស្រាយបច្ចេកទេស។

## D&IP

១ ផ្តល់ជំនួយផ្នែកបច្ចេកទេស ឬហិរញ្ញវត្ថុ ដើម្បីកែលម្អរមុខងារ TnT អោយកាន់តែប្រសើរ។

# ៤. កង្វះការណែនាំ

## PDH

១ វិនិយោគលើការផលិត ឬការធ្វើបច្ចុប្បន្នភាពសម្ភារៈបណ្ដុះបណ្ដាល TnT ជាភាសាខ្មែរដែលមានគុណភាពខ្ពស់ និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ TnT បច្ចុប្បន្ន និងអ្នកដែលនឹងត្រូវបប្រើប្រាស់ TnT អោយទូលំទូលាយ។

២ ធ្វើការវាយតម្លៃតម្រូវការ និងវគ្គបណ្ដុះបណ្ដាលផ្ទាល់សម្រាប់សាលាដែលត្រូវការការអភិវឌ្ឍន៍សមត្ថភាពបន្ថែមលើការប្រើប្រាស់ TnT ។

៣ សហការជាមួយភាគីពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ ដើម្បីបង្កើនការចូលរួម  ការផ្សព្វផ្សាយអន្តរស្ថាប័ន និងការចែករំលែកការអនុវត្តល្អៗ។



# ៥. កង្វះការចូលរួមពីអ្នកពាក់ព័ន្ធ

## PDH

១ ប្តេជ្ញាបន្តផ្តល់ការបណ្តុះបណ្តាលលើការប្រើប្រាស់ TnT និងជំនួយបច្ចេកទេសផ្សេងទៀត។

២ ពិចារណាឡើងវិញអំពីតួនាទី និងការចូលរួមរបស់ DoE, PoE, និង SSC/SMC នៅក្នុងប្រព័ន្ធ TnT ដើម្បីបង្កើនការសម្រេចបាននូវតម្លាភាព និងគណនេយ្យភាពក្នុងការងារ។

## DoE & PoE

១ ប្តេជ្ញាបន្តការសម្របសម្រួល និងបណ្តុះបណ្តាលTnTដល់នាយកសាលា។




## SSC

១ ប្តេជ្ញាបន្តការសម្របសម្រួល និងបណ្តុះបណ្តាលTnTដល់នាយកសាលា។

## SD

១ ព្យាយាមស្រាវជ្រាវ និងស្វែងយល់បន្ថែមអំពីមុខងារ TnT។

# ៦. អត្រាផ្លាស់ប្តូរសៀវភៅសិក្សាគោលមិនទាន់ឆ្លើយតបតាមបរិបទ

## RGC

១ ធ្វើការសិក្សាស្រាវជ្រាវថ្មីពីអត្រាផ្លាស់ប្តូរសៀវភៅសិក្សាគោល ដែលសមស្របតាមបរិបទ។




## PoE & DoE , PDH , SD & SSC

១ ចូលរួមអោយសកម្មក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍ ប្រសិនបើមានការសិក្សា ឬការពិនិត្យឡើងវិញលើគុណភាព អាយុកាល និងការគ្រប់គ្រងសៀវភៅសិក្សាគោល។







## PRIVATE SECTOR , D&IP

១ ចូលរួម ឬគាំទ្រក្នុងការសិក្សា ឬការស៊ើបអង្កេតទាក់ទងនឹងគុណភាព និងអាយុកាលសៀវភៅសិក្សាគោល។

# ៧. អត្រាផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សិស្ស មិនមានភាពបទបែន




## RGC

១ បង្កើនការវិនិយោគ និងថវិការជាតិបន្ថែមទៀតក្នុងការកែលម្អប្រព័ន្ធអប់រំ។




## MOEYS

១ សូមអោយមានការសហការពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធ្វើការពិនិត្យឡើងវិញ ឬកែប្រែអត្រាផ្គត់ផ្គង់សៀវភៅសិក្សាគោលទៅដល់សិស្ស។

២ បែងចែកថវិការបន្ថែមទៀតដើម្បីកែលម្អខ្លឹមសារនិងគុណភាពរូបវន្តសៀវភៅសិក្សាគោល ព្រមទាំងការគ្រប់គ្រងទុកដាក់សៀវភៅសិក្សា ។

# ៨. ការផ្លាស់ប្តូរបរិបទ

## MOEYS

១ បែងចែកគ្រូបង្រៀនបន្ថែមទៅសាលាដែលពិបាករក បុគ្គលិក ឬខ្វះធនធាន។

២ បង្កើតវិធីសាស្រ្តគ្រប់គ្រងធនធានមនុស្សរបស់សាលា អោយមានលក្ខណៈជាប្រព័ន្ធ។

## PDH

១ ធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ TnT និងអ្នកប្រើប្រាស់ TnT ។

២ ធ្វើបច្ចុប្បន្នភាពលេខទំនាក់ទំនងរបស់នាយកសាលា ឱ្យបានញឹកញាប់ និងផ្តល់ការបណ្តុះបណ្តាលដល់អ្នក ដែលទើបតែចូលកាន់តំណែង។




## DoE & PoE

១ ជួយពិនិត្យតាមដាននូវការផ្លាស់ប្តូរ ធនធានមនុស្សរបស់សាលា។

២ ជួយផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរ បុគ្គលិកនៅក្នុងសាលាដល់ PDH ។

## SD

១ ធ្វើបច្ចុប្បន្នភាពស្ថានភាពសាលានិង បុគ្គលិកឱ្យបានញឹកញាប់ទៅ DoE និង PoE ។

USAID FROM THE AMERICAN PEOPLE

SHARE Supporting Holistic & Actionable Research in Education

UNIVERSITY OF NOTRE DAME

CDRI Cambodia Development Resource Institute